**Regional ToT, Kathmandu, Nepal, 23-26 February 2018**
**ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់**
**ទីក្រុង កាត្មាន់ឌុ ប្រទេសនេប៉ាល់ ថ្ងៃទី២៣-២៦ ខែកុម្ភៈ ឆ្នាំ២០១៨**

## Handout 2.3 Good practices: Domestic workers' organizations helping to stop child labour in domestic work and protecting young domestic Workers *(Source: IDWF/ILO Handbook on child labour in domestic work)*

## ឯកសារ២.៣ ការអនុវត្តល្អ៖ អង្គការអ្នកធ្វើការតាមផ្ទះ ជួយបញ្ឈប់ពលកម្មកុមារក្នុងការងារតាមផ្ទះនិងការការពារអ្នកធ្វើការតាមផ្ទះវ័យក្មេង *(ប្រភព៖ សៀវភៅ IDWF/ILO ស្តីពីពលកម្មកុមារក្នុងការងារតាមផ្ទះ)*

បទពិសោធន៍ក្នុងកន្លែងផ្សេងៗគ្នានៅជុំវិញពិភពលោក បានបង្ហាញថាថា ការតស៊ូមតិប្រកបដោយប្រសិទ្ធភាពជាមួយកុមារធ្វើការងារតាមផ្ទះនិងក្នុងនាមកុមារធ្វើការងារតាមផ្ទះ គួរធ្វើរួមគ្នាជាមួយនឹងការផ្តល់សេវាកម្មប្រកបដោយប្រសិទ្ធភាព គឺសេវាកម្មដែលការពារកុមារ។ សេវាកម្មទាំងនេះ កសាងចំណេះដឹងនិងទំនុកចិត្តដល់កុមារធ្វើការងារតាមផ្ទះ និងបង្កើតទំនុកចិត្តរបស់ឪពុកម្តាយ និយោជក និងដៃគូសំខាន់ៗក្នុងសហគមន៍របស់ពួកគេ។ ដូចគ្នានេះដែរ ទោះបីមានការផ្តល់ប្រយោជន៍ដ៏មានតម្លៃដល់បុគ្គលក៏ដោយ ក៏ការផ្តល់សេវាកម្មដែលគ្មានការតស៊ូមតិ មិនអាចផ្តល់នូវការផ្លាស់ប្តូរប្រកបដោយចីរភាពទូលំទូលាយបាននោះទេ។

## ការពឹងផ្អែកគ្នាទៅវិញទៅមកអំពីការតស៊ូមតិនិងសកម្មភាពផ្តល់សេវាកម្ម៖ ចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ (NDWM), ប្រទេសឥណ្ឌា

ក្នុងប្រទេសឥណ្ឌា សេវាកម្មជាច្រើនសម្រាប់កុមារធ្វើការតាមផ្ទះ ត្រូវបានបង្កើតឡើងដោយស្ថាប័ននានាថ្នាក់ជាតិនៃចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ។ សេវាកម្មកម្មទាំងនេះ មានចាប់ពីការចុះឈ្មោះចូលរៀននិងការគាំទ្រការអប់រំសម្រាប់កុមារធ្វើការតាមផ្ទះនៅតាមសាលារៀន រហូតដល់ការបណ្តុះបណ្តាលជំនាញ, ការសង្គ្រោះនិងអន្តរាគមន៍ពេលមានវិបត្តិ, ការគាំទ្រទៅវិញទៅមក និងការផ្តល់ការប្រឹក្សាយោបល់ ព្រមទាំង ការចូលរួមក្នុងការសម្តែងនៅតាមផ្លូវ និងសកម្មភាពកីឡាផ្សេងៗ។ សេវាកម្មទាំងនេះ មានអមដោយការពិភាក្សាជាមួយបុគ្គលនិងការពិភាក្សាជាក្រុម ការប្រជុំ និងវគ្គបណ្តុះបណ្តាល ដើម្បីលើកកម្ពស់ការយល់ដឹងដល់ឪពុកម្តាយ ថ្នាក់ដឹកនាំសហគមន៍ និងគ្រូបង្រៀន។ កុមារពាក់ព័ន្ធជាច្រើន បានបង្កើតក្លឹបកុមារជាច្រើន។ កុមារទាំងនោះមានភាពសកម្មនៅក្នុងសកម្មភាពយុទ្ធនាការរបស់ចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ ដូចជា ការប្រមូលផ្តុំ ការធ្វើសន្និសីទកាសែត ការសន្ទនាជាមួយមន្ត្រីរដ្ឋាភិបាល ការប្រមូលហត្ថលេខា ដើម្បីហាមឃាត់ពលកម្មកុមារនិងដើម្បីការអនុម័តច្បាប់ការពារអ្នកធ្វើការតាមផ្ទះទាំងអស់។

## សកម្មភាពដោយចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ

ចាប់តាំងពីឆ្នាំ២០០៦ ចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ បានចាត់ចែងឲ្យមានមណ្ឌលក្រៅប្រព័ន្ធសម្រាប់កុមារធ្វើការងារតាមផ្ទះ និងអ្នកបោះបង់ការសិក្សា ឬកុមារមិនបានចូលសាលារៀន (អាយុ៦ ដល់១៤ឆ្នាំ)។ ចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ ប្រមូលកុមារចូលរៀនមុខវិជ្ជាផ្សេងៗគ្នា ដោយគ្រូដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ពួកគេអាចទៅរៀនបីម៉ោង ក្នុងមួយថ្ងៃ ៦ថ្ងៃក្នុងមួយសប្តាហ៍។ កុមារទទួលបានសម្ភារៈសិក្សា សៀវភៅ និងអាហារដែលមានជីវជាតិអាហារូបត្ថម្ភ។ ដំបូង គ្រូបង្រៀននិងក្រុមចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ ជួបជាមួយឪពុកម្តាយដើម្បីលើកកម្ពស់ការយល់ដឹងអំពីសារៈសំខាន់នៃការអប់រំនិងផលប្រយោជន៍ក្នុងការបញ្ជូនកូនឲ្យទៅរៀននៅមណ្ឌលដែលកុមារអាចរៀនជាមួយអ្នកមានអាយុស្របាលគ្នា និងត្រៀមខ្លួនដើម្បីចូលរៀនក្នុងប្រព័ន្ធ។

គ្រូបង្រៀន មានការទាក់ទងជាទៀងទាត់ជាមួយនឹងសាលានៅមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០៦មក សិស្សប្រហែល៧០០នាក់ បានឆ្លងកាត់មណ្ឌលទាំងនេះ។ ដោយសារតែម្តាយរបស់កុមារទាំងនេះ ជាអ្នកធ្វើការតាមផ្ទះដោយផ្ទាល់ខ្លួននោះ ពួកគេតែងទទួលចូលរួមក្នុងការពិភាក្សាបែបស្លាបនាជាមួយអ្នកតស៊ូមតិរបស់ចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ។

ការអនុវត្តល្អមួយផ្សេងទៀត គឺកម្មវិធីលើកកម្ពស់ការយល់ដឹងប្រឆាំងនឹងការជួញដូរកុមារនិងស្ត្រី។ នៅក្នុងស្រុកដែល ការជួញដូរមានភាពរីកដាល ចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ មានកម្មវិធីរួមមួយដែលរួមមានការចែកខិត្តបណ្ណ ការសម្តែងតាមផ្លូវ ការដាក់បង្ហាញផ្ទាំងរូបភាព និងយុទ្ធនាការប្រព័ន្ធផ្សព្វផ្សាយ។ នៅតំបន់មួយចំនួន គណៈកម្មការយុវជន ត្រូវបានបង្កើតឡើងដោយតាមដានការជួញដូរកុមារនិងកំណត់រកឲ្យឃើញអ្នកជួញដូរនិងធ្វើការរិះគន់ដល់អ្នកជួញដូរនោះ។

**មេរៀនទទួលបាន៖** មេរៀនដែលទទួលបានពីចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ មានដូចជា៖

- ការកសាងភាពស្និទ្ធស្នាលជាមួយឪពុកម្តាយ គឺជាអាទិភាពទីមួយ
- ទាក់ទងនិងរៀបចំសកម្មភាពជាប្រចាំសម្រាប់ឪពុកម្តាយនិងកុមារ មានសារៈសំខាន់ខ្លាំងណាស់
- ការប្រមូលទិន្នន័យ គួរតែជាសកម្មភាពជាបន្តបន្ទាប់មិនដាច់
- ការទទួលស្គាល់កុមារក្នុងការបង្កើតក្រុមរបស់ពួកគេ និងកសាងអ្នកដឹកនាំក្នុងចំណោមក្រុមកុមារ មានសារៈសំខាន់
- ការបណ្តុះបណ្តាលអំពីការលើកទឹកចិត្ត សម្រាប់អ្នកធ្វើការតាមផ្ទះពេញវ័យ ស្តីពីការការពារកុមារនិងការដោះស្រាយករណីនៃការរំលោភបំពាននិងការកេងប្រវ័ញ្ច គឺជាការចាំបាច់ត្រូវតែធ្វើ
- ការចងបណ្តាញជាមួយក្រុមដែលមានទឹកចិត្តដូចគ្នា ជាការសំខាន់

***********

## ករណីចលនាអ្នកធ្វើការតាមផ្ទះថ្នាក់ជាតិ នៅរដ្ឋប៊ីហា

ក្នុងរដ្ឋប៊ីហា (រដ្ឋដែលមានប្រជាជនច្រើនជាងគេទីបី នៅប្រទេសឥណ្ឌា) អ្នកធ្វើការតាមផ្ទះ ដែលស្ទើរតែទាំងអស់ជាស្ត្រី រស់នៅក្នុងតំបន់អាណាធិបតេយ្យជាមួយគ្រួសាររបស់ពួកគេ ទោះបីជាពេលវេលាភាគច្រើននៅ

កន្លែងធ្វើការក៏ដោយ។ ប្ដីរបស់ពួកគេ ធ្វើការតាមដែលអាចរកបាន ដូចជា អូសឆៃកែវ គូរគំនូរ ជាងកំបោរ ជាដើម ហើយការផឹកស្រា គឺជាសកម្មភាពរីកសាយភាពខ្លាំង។ កូនរបស់ពួកគេ មិនទទួលបានសិទ្ធិជាមូលដ្ឋានទេ ដូចជា សិទ្ធិទទួលបានការអប់រំ សុខភាព អនាម័យ ហើយនៅពេលដែលកុមារធ្វើជាពលករ ពួកគេមិនបានទទួលសិទ្ធិការពារជៀសផុតពីការរំលោភបំពាននិងការកេងប្រវ័ញ្ចនោះទេ។

កុមារីស្ទើរតែទាំងអស់ (ជិត ៩៩%) ចូលទៅធ្វើការងារតាមផ្ទះ។ កុមារីខ្លះមានអាយុ៤ឆ្នាំ ទៅជាមួយម្ដាយរបស់ពួកគេ ហើយពេលធំបន្តិច ក៏ចាប់ផ្ដើមធ្វើការខ្លួនឯង។ ការសិក្សាថ្មីៗមួយដោយ ចលនាសង្គ្រោះកុមារក្នុងប្រទេសឥណ្ឌា បានបង្ហាញថា កុមារជាច្រើនក្នុងចន្លោះអាយុ ៦ ដល់ ១៤ឆ្នាំ ដែលបានចុះឈ្មោះចូលរៀននៅក្នុងស្រុក ដារជង៉ា តាមពិតទៅកំពុងធ្វើការសងបំណុលគេនៅក្នុងក្រុងញូដេលី។ ការសិក្សានេះ បានលាតត្រដាងថា កុមារចន្លោះអាយុ ៦ ដល់ ១៤ ឆ្នាំ ចំនួន២៥% នៅក្រៅសាលារៀន។ ទោះបីជាការផ្ដល់ការងារឲ្យកុមារក្រោមអាយុ ១៤ឆ្នាំ ក្នុងការងារតាមផ្ទះឬការងារប្រភេទណាក៏ដោយ ត្រូវបានហាមឃាត់ក៏ដោយ ក៏អាជ្ញាធររដ្ឋមាន "ភាពទន់ភ្លន់" ជាមួយនិយោជករបស់កុមារណាស់។

មានកុមារធ្វើការតាមផ្ទះពេញម៉ោង ដែលត្រូវគេជួញដូរមកពីតំបន់ជនបទនិងតំបន់កុលសម្ព័ន្ធ ហើយដាក់ឬលក់ទៅឲ្យគ្រួសារផ្សេង នៅក្នុងទីក្រុងរដ្ឋធានី ប៉ាត់ណា និងតំបន់ផ្សេងៗទៀត។ កុមារទាំងនេះ ច្រើនតែត្រូវបានគេរំលោភបំពានផ្លូវកាយ ផ្លូវភេទ ឬផ្លូវអារម្មណ៍ ហើយភាគច្រើនមិនបានទទួលប្រាក់កម្រៃ និងមិនអាចចេញទៅខាងក្រៅឬទាក់ទងទៅគ្រួសាររបស់ពួកបានទេ។ ករណីនៃការបាត់ខ្លួនកុមារពីតំបន់កុលសម្ព័ន្ធ មានកើតឡើងជាហូហែ។

**សាលាជំនួស សម្រាប់កុមារនិងមនុស្សពេញវ័យធ្វើការតាមផ្ទះ÷ ចាឡា ភីអធី** (Jala PRT) **បណ្ដាញអ្នកធ្វើការតាមផ្ទះ, ឥណ្ឌូណេស៊ី**

ចាឡា ភីអធី (Jala PRT) គឺជាបណ្ដាញតស៊ូមតិមួយរបស់អ្នកធ្វើការងារតាមផ្ទះនៅថ្នាក់ជាតិ ដែលបានបង្កើតឡើងក្នុងខែកក្កដា ឆ្នាំ២០០៤។ បណ្ដាញនេះ មានអង្គការមិនមែនរដ្ឋាភិបាលនិងក្រុមនានាចំនួន២៦ ដែលផ្ដោតលើការការពារអ្នកធ្វើការងារតាមផ្ទះ។ បណ្ដាញនេះ គ្រប់គ្រងសាលាជំនួសសម្រាប់អ្នកធ្វើការងារតាមផ្ទះ ឈ្មោះ រ៉ាន់ពន់ ក្នុងទីក្រុងយ៉ូយ៉ាការតា។ សាលារៀន អនុវត្តកម្មវិធីសម្រាង់អ្នកធ្វើការតាមផ្ទះវ័យក្មេង ដែលភាគច្រើនមានអាយុ១៥ ឬលើសពីនេះ លើមុខវិជ្ជាផ្សេងៗដូចជា ការបើកបរ ភាសាអង់គ្លេស កុំព្យូទ័រ ការគ្រប់គ្រងក្នុងផ្ទះ ការមើលថែទារក គិលានុបដ្ឋាកបឋម សុខភាពនិងសន្តិសុខ សិទ្ធិបន្តពូជ ជាដើម។ បន្ថែមពីលើនេះ សាលារៀននេះ ក៏មានវគ្គអំពីការសម្ដែង តន្ត្រី និងកីឡា។ អ្វីដែលធ្វើឲ្យសាលារៀននេះ មានលក្ខណៈពិសេសនោះ គឺដោយសារតែវាផ្ដោតទៅលើការលើកកម្ពស់ការយល់ដឹងអំពីអ្នកធ្វើការងារតាមផ្ទះ អំពីសិទ្ធិរបស់ពួកគេ និងអំពីរបៀបការពារសិទ្ធិទាំងនេះ។ វគ្គស្ដីពីសិទ្ធិមនុស្ស សិទ្ធិការងារ និងសិទ្ធិកុមារ សមភាពយេនឌ័រ ពលរដ្ឋវិជ្ជា ច្បាប់ និងការកសាងនិងពង្រឹងអង្គការអ្នកធ្វើការតាមផ្ទះ ត្រូវបានបញ្ចូលទៅក្នុងកម្មវិធី។

កម្មវិធីរៀនសូត្ររបស់ ចាឡា ភីអធី (Jala PRT) បានជំរុញទឹកចិត្តឲ្យសមាជិកបណ្ដាញផ្សេងទៀត ឲ្យបង្កើតសាលាស្រដៀងគ្នានេះ សម្រាប់កុមារធ្វើការងារតាមផ្ទះ ហើយវាបានពង្រឹងកិត្តិយសរបស់ចាឡា ភីអធី (Jala

PRT) ថាជាអ្នកតស៊ូមតិក្នុងការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារក្នុងការងារតាមផ្ទះ និងក្នុងការការពារនិងចងក្រងអ្នកធ្វើការងារតាមផ្ទះវ័យក្មេង។ ការិយាល័យពលកម្មមនុស្ស (នាយកដ្ឋានការងារ) និងរដ្ឋាភិបាលខេត្តយ៉ូយ៉ាការតាចាត់ទុកកិច្ចសន្យាការងាររបស់អង្គការនិងលក្ខខណ្ឌតម្រូវការជាស្តង់ដារសម្រាប់ការការពារ ជាគម្រូក្នុងការបង្កើតទំនាក់ទំនងការងារល្អ រវាងនិយោជកនិងអ្នកធ្វើការងារតាមផ្ទះ ហើយជាលទ្ធផល វាបង្កើតបាននូវលក្ខខណ្ឌការងារល្អជាងមុន សម្រាប់អ្នកធ្វើការតាមផ្ទះវ័យក្មេង។

## ការកសាងសម្ព័ន្ធនិងការពង្រឹងកិច្ចសហប្រតិបត្តិការ៖ ស៊ូម៉ាពី ហ្វីលីពីន

បង្កើតឡើងក្នុងឆ្នាំ១៩៩៥ ស៊ូម៉ាពី គឺជាអង្គការអ្នកធ្វើការងារតាមផ្ទះដំបូងគេក្នុងប្រទេសហ្វីលីពីន។ ស៊ូម៉ាពី ត្រូវបានបង្កើតឡើងដោយមានការគាំទ្រពីអង្គការវេទិកាវិសាយ៉ាន (Visayan Forum) ដែលជាអង្គការមិនមែនរដ្ឋាភិបាលមួយ ធ្វើការដើម្បីពង្រឹងភាពអង់អាចរបស់អ្នកចំណាកស្រុកដែលងាយរងគ្រោះ ជាពិសេស ជនរងគ្រោះដោយសារការជួញដូរមនុស្ស និងទាសភាពតាមផ្ទះ និងដើម្បីប្រឆាំងពលកម្មកុមារ។ ការងារចងក្រងរបស់អង្គការស៊ូម៉ាពី មានទិសដៅក្នុងការឈានចូលទៅឲ្យដល់អ្នកធ្វើការតាមផ្ទះវ័យក្មេងនិងចងក្រងពួកគេ ដែលភាគច្រើនជាស្ត្រី ដោយពួកគេប្រមូលផ្តុំគ្នានៅថ្ងៃអាទិត្យដែលជាថ្ងៃសម្រាកពីការងារ។ អង្គការស៊ូម៉ាពី រួមមានក្រុមស្នូលរបស់បណ្តាញដែលមានមូលដ្ឋាននៅតាមសួន តាមសាលារៀន តាមព្រះវិហារ និងតាមទីតាំងផ្ទេរការជួញដូរ។ ពួកគេបានរួមគ្នា និយាយលើកឡើងអំពីស្ថានភាពលំបាកលំបិនរបស់អ្នកធ្វើការតាមផ្ទះ ជាពិសេស កុមារធ្វើការងារតាមផ្ទះ។ ស៊ូម៉ាពី ដឹកនាំផ្លូវតាមរបៀបវារៈ១០ចំណុច ស្តីពីការងារល្អប្រសើរសម្រាប់អ្នកធ្វើការងារតាមផ្ទះ ដោយក្នុងនោះរួមមានទាំង កំណែទម្រង់ច្បាប់ វិធានការប្រឆាំងការជួញដូរ តម្រូវការក្នុងការធានាឲ្យមានចំណាកស្រុកដោយសុវត្ថិភាព និងការផ្តល់អាទិភាពទៅលើការអប់រំសម្រាប់កុមារធ្វើការងារតាមផ្ទះ។

ចំណុចខ្លាំងជាពិសេសរបស់ ស៊ូម៉ាពី គឺសមត្ថភាពក្នុងការចូលរួមពាក់ព័ន្ធជាមួយស្ថាប័នសង្គមស៊ីវិលផ្សេងទៀត និងការបញ្ចុះបញ្ចូលអាជ្ញាធរថ្នាក់តំបន់ ក្នុងការកំណត់ឲ្យបាននូវចន្លោះប្រហោងផ្នែកច្បាប់។ ឧទាហរណ៍ ក្នុងអំឡុងពេលបង្កើតនិងអនុម័តច្បាប់ស្តីពីអ្នកធ្វើការតាមផ្ទះក្នុងប្រទេសហ្វីលីពីន អង្គការស៊ូម៉ាពី បានអាសនៈជាទៀងទាត់មួយនៅក្នុងក្រុមការងារបច្ចេកទេសថ្នាក់ជាតិ ដែលធ្វើការពិភាក្សាអំពីច្បាប់នោះ និងផ្តល់ឲ្យតំណាងរបស់ខ្លួននូវតួនាទីសម្រេចចិត្តគន្លឹះមួយនៅថ្នាក់ជាតិ ក្នុងដំណើរការដែលឈានទៅដល់ការអនុម័តច្បាប់ដ៏សំខាន់នេះ នៅក្នុងខែមករា ឆ្នាំ២០១៣។ ទន្ទឹមពេលជាមួយគ្នានេះដែរ សមាជិកអង្គការស៊ូម៉ាពី បានជួយដឹកនាំការតស៊ូមតិរបស់សង្គមស៊ីវិល ឲ្យមានការផ្តល់សច្ចាប័នអនុសញ្ញា ILO ស្តីពីអ្នកធ្វើការតាមផ្ទះ ឆ្នាំ២០១១ (អនុសញ្ញាលេខ ១៨៩) ដែលផ្តល់សច្ចាប័នដោយរដ្ឋាភិបាលហ្វីលីពីនក្នុងឆ្នាំ២០១២ ដែលជាប្រទេសទីពីរក្នុងពិភពលោកដែលបានផ្តល់សច្ចាប័នអនុសញ្ញានេះ។ ថ្នាក់ដឹកនាំអង្គការស៊ូម៉ាពីម្នាក់ បាននិយាយថា "សមាជិករបស់យើងជាច្រើនកំពុងធ្វើការចងក្រង និងនិយាយជាមួយមន្ត្រីនយោបាយនិងមន្ត្រីសាធារណៈ ទាមទារសិទ្ធិកុមារធ្វើការងារតាមផ្ទះ ព្រមទាំងធ្វើការបញ្ចុះបញ្ចូល។ ឆ្នាំមុន ក្នុងអំឡុងពេលសុន្ទរកថារបស់លោកប្រធានាធិបតី គាត់បានប្រកាសថា ដល់ពេលដែលយើងត្រូវមានច្បាប់ជាតិមួយដើម្បីការពារកុមារធ្វើការតាមផ្ទះហើយ ដូច្នេះ រដ្ឋាភិបាលបានទទួលស្គាល់ថា ការគាំទ្រដល់សេចក្តីត្រូវការរបស់កុមារធ្វើការតាមផ្ទះ ជាការសំខាន់"។

***********

## រឿងរបស់អាណុល ថ្នាក់ដឹកនាំអង្គការស៊ូម៉ាតី មកពីទីក្រុងសេប៊ូ

"ខ្ញុំបានចាប់ផ្ដើមក្នុងនាមជាសមាជិកម្នាក់របស់អង្គការស៊ូម៉ាតី នៅពេលដែលខ្ញុំរៀនឆ្នាំទីមួយនៅវិទ្យាល័យ។ ខ្ញុំគឺជាកុមារធ្វើការងារតាមផ្ទះម្នាក់ នៅក្នុងទីក្រុងសេប៊ូ។ ខ្ញុំមិនបានដឹងថា និយោជករបស់ខ្ញុំនឹងមិនធ្វើបាបខ្ញុំនោះទេ។ គេមិនឲ្យខ្ញុំដេកលើគ្រែក្នុងបន្ទប់ទេ គឺគេឲ្យខ្ញុំដេកនៅក្នុងហាង ហើយខ្ញុំត្រូវហូបអាហារដែលនៅសល់។ គេយកខ្ញុំទៅធ្វើជាបាវសាក់សម្រាប់វ៉េ។ ថ្វីត្បិតតែយ៉ាងនេះក្ដី ខ្ញុំនៅតែទៅសាលារៀន ហើយនាយកសាលាបានជួយខ្ញុំ។ នៅពេលនោះហើយដែលខ្ញុំបានជួបអង្គការវេទិកាវិសាយ៉ាននិងអង្គការស៊ូម៉ាតី ហើយគេបានតម្រង់ទិសប្រាប់ខ្ញុំថាអង្គការស៊ូម៉ាតី ធ្វើអ្វីខ្លះ និងប្រាប់ខ្ញុំអំពីសិទ្ធិកុមារធ្វើការងារតាមផ្ទះ។ ពួកគេបានចាក់វីដេអូមួយឲ្យខ្ញុំមើល ហើយពេលនោះ គឺជាពេលដែលខ្ញុំដឹងថា អ្វីដែលនិយោជកធ្វើមកលើខ្ញុំ គឺជាទង្វើខុសឆ្គង និងដឹងថាខ្ញុំមានសិទ្ធិ។ នៅពេលដែលខ្ញុំដឹងថា ខ្ញុំត្រូវគេបំពាន ខ្ញុំបានចាប់ផ្ដើមធ្វើជាអ្នកស្ម័គ្រចិត្តរបស់អង្គការស៊ូម៉ាតី។ បុគ្គលិកម្នាក់បានសួរខ្ញុំថាតើខ្ញុំចង់ដាក់ពាក្យបណ្ដឹងទៅលើនិយោជករបស់ខ្ញុំឬទេ។ ខ្ញុំក៏ឆ្លើយថាទេ ពីព្រោះ ខ្ញុំមិនចង់ឲ្យនរណាម្នាក់ឈឺចាប់ទេ។ ដូច្នេះ ខ្ញុំបន្តធ្វើការរហូតដល់ថ្ងៃមួយដែលនិយោជករបស់ខ្ញុំ យកកាំភ្លើងមកខ្ញុំ ហើយបានកេះកៃកាំភ្លើងនោះ (សំណាងល្អ វាមិនត្រូវចំខ្ញុំ)។ ដូច្នេះ ខ្ញុំក៏បានដាក់ពាក្យប្ដឹង ហើយនៅក្នុងអំឡុងពេលសវនាការជាសាធារណៈ ខ្ញុំបានអះអាងអំពីសិទ្ធិរបស់ខ្ញុំ។ អ្នកប្រឹក្សាយោបល់ម្នាក់បានកត់សម្គាល់ជាពិសេសលើករណីរបស់ខ្ញុំ និងបានជួយខ្ញុំចេញផុតពីស្ថានភាពដ៏លំបាកនោះ។ គឺនៅពេលនោះហើយដែលខ្ញុំបានក្លាយទៅជាថ្នាក់ដឹកនាំម្នាក់។ ខ្ញុំបានរៀនចប់វិទ្យាល័យ ហើយបន្ទាប់មក អង្គការស៊ូម៉ាតី បានជួយខ្ញុំតាមរយៈការផ្ដល់អាហារូបករណ៍រៀនខាងផ្នែកផ្សារដែក ហើយបច្ចុប្បន្ននេះ ខ្ញុំគឺជាជាងផ្សារដែកដែលមានអាជ្ញាប័ណ្ណម្នាក់"។

## ការចូលទៅដល់កុមារធ្វើការតាមផ្ទះ តាមរយៈការឲ្យនិយោជកមានការចូលរួមពាក់ព័ន្ធ, វ៉ូតេសាវ៉ា ប្រទេសតង់ហ្សានៀ

វ៉ូតេសាវ៉ា គឺជាក្រុមមួយដឹកនាំដោយយុវជនដែលជាអតីតកុមារធ្វើការតាមផ្ទះនិងកុមារកំពុងធ្វើការងារតាមផ្ទះ នៅទីក្រុងម៉្វាន់ហ្សា ប្រទេសតង់ហ្សានៀ ហើយក្រុមនេះបង្កើតឡើង ដើម្បីពង្រឹងភាពអង់អាចដល់កុមារធ្វើការងារតាមផ្ទះ ក្នុងការតស៊ូមតិទាមទារសិទ្ធិរបស់ពួកគេ និងដើម្បីរស់នៅរួចផុតពីការរំលោភបំពាន អំពើហិង្សាផ្លូវភេទ និងពលកម្មកុមារ គ្រប់ទម្រង់។ រហូតមកដល់ពេលនេះ ក្រុមយុវជនវ៉ូតេសាវ៉ា បានជ្រើសរើសនិងបណ្ដុះបណ្ដាលអតីតកុមារធ្វើការតាមផ្ទះនិងកុមារកំពុងធ្វើការងារតាមផ្ទះរាប់រយនាក់ ដើម្បីបង្កើត**បណ្ដាញអ្នកតស៊ូមតិ** ដែលជួបជុំគ្នាបីខែម្ដងជាទៀងទាត់ ដើម្បីពិភាក្សាអំពីបញ្ហាដែលកំពុងកើតឡើង និងដើម្បីសម្រេចចិត្តទៅលើយុទ្ធសាស្ត្រ។ ក្រុមនេះ ក៏ជួយដល់សមាជិករបស់ខ្លួន ក្នុងការអភិវឌ្ឍន៍ជំនាញស្វែងរកការងារជំនួស។

តាមរយៈសមាជិក ក្រុមយុវជនវ៉ូតេសាវ៉ា បានសង្គ្រោះនិងផ្ដល់ប្រឹក្សាយោបល់ដល់កុមារធ្វើការតាមផ្ទះមួយចំនួនដែលត្រូវគេរំលោភបំពាន។ ក្រុមនេះបានចូលរួមជាមួយមន្ត្រីមូលដ្ឋាន ក្នុងការបង្កើតលក្ខន្តិកៈដើម្បីការពារកុមារធ្វើការងារតាមផ្ទះ និងបានចូលរួមជាប្រចាំក្នុងកម្មវិធីពិភាក្សាតាមវិទ្យុ និងក្នុងសារព័ត៌មាន។ ក្រុមយុវជនវ៉ូតេសាវ៉ា ក៏ស្ថិតនៅជួរមុខគេក្នុងការខិតខំប្រឹងប្រែង ដើម្បីបង្កើតសម្ព័ន្ធអ្នកធ្វើការតាមផ្ទះតង់ហ្សានៀ ដែលបានចុះបញ្ជីជាផ្លូវការក្នុងឆ្នាំ២០១២ដែរ។

**********

**ក្រុមយុវជនទុំតេសាវ៉ា ធ្វើឲ្យនិយោជកមានការចូលរួមពាក់ព័ន្ធ ដើម្បីទទួលស្គាល់សិទ្ធិកុមារ៖**

"នៅពេលយើងចាប់ផ្តើម និយោជកភាគច្រើនមិននិយាយត្រង់ដោយចំហ ថាពួកគេមានកុមារធ្វើការតាមផ្ទះនោះទេ។ ពួកគេថា កុមារទាំងនោះជាសាច់ញាតិ ហើយកុមារទាំងនោះ ក៏យល់ស្របថាដូច្នោះដែរ ដោយខ្លាចថា បើនិយាយការពិត នាំឲ្យបាត់បង់ការងារ។ បួនឆ្នាំមុន វាពិតជាមានការលំបាកខ្លាំងណាស់ ក្នុងការរកឲ្យឃើញកុមារទាំងនេះ ដោយសារតែនិយោជក លាក់កុមារទាំងនោះ។ កុមារខ្លួនឯង ក៏នៅស្ងៀម គឺពួកគេមិនទាន់ត្រៀមខ្លួនរួចរាល់ក្នុងការពិភាក្សាបញ្ហារបស់ពួកគេដោយបើកចំហនៅឡើយទេ ហើយវាហាក់ដូចជាពួកគេបានសុខចិត្តទទួលយកស្ថានភាពនេះដោយខ្លាំងឯងហើយ"។

"ចាប់តាំងពីពេលនោះមក យើងអាចចូលទៅដល់កុមារធ្វើការងារតាមផ្ទះ តាមរយៈការធ្វើឲ្យនិយោជកដឹងអំពីសិទ្ធិរបស់កុមារ។ យើងបានប្រើប្រាស់ច្បាប់ស្តីពីកុមារឆ្នាំ២០០៩ ជាចំណុចចាប់ផ្តើមដើម្បីឲ្យនិយោជកអនុញ្ញាតិឲ្យកុមារត្រឡប់ទៅសាលារៀនវិញ ហើយបានបង្កើតក្រុមនិយោជក ដើម្បីតាមដាននិយោជក និងធានាថានិយោជក ប្រកាន់ខ្ជាប់ទៅលើសិទ្ធិកុមារ។ និយោជិក១២នាក់ បានចូលរួមពាក់ព័ន្ធនៅក្នុងឆ្នាំ២០០៩ ហើយបួនឆ្នាំក្រោយមក ចំនួននិយោជកបានកើនឡើងលើស២០០នាក់"។